# ព្រះរាជក្រម

នស/រកម/១១១៦/០១៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការគ្រប់គ្រងអ្នកប្រកបវិជ្ជាជីវៈវិស័យសុខាភិបាល ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៧ ខែតុលា ឆ្នាំ២០១៦ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១៦ នាសម័យប្រជុំពេញអង្គលើកទី៩ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅៈ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ច្បាប់
# ស្តីពី
# ការគ្រប់គ្រងអ្នកប្រកបវិជ្ជាជីវៈ
# វិស័យសុខាភិបាល

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលបំណងការពារសុខភាព និងសុវត្ថិភាពរបស់ប្រជាជនតាមរយៈ ការផ្តល់នូវយន្តការក្នុងការធានាថា អ្នកប្រកបវិជ្ជាជីវៈសុខាភិបាលទាំងអស់មានគុណវុឌ្ឍិ សមត្ថភាព និងសម្បទាគ្រប់គ្រាន់ក្នុងការប្រកបវិជ្ជាជីវៈរបស់ខ្លួន ។

**មាត្រា ២.-**

ច្បាប់នេះមានគោលដៅកំណត់អំពីវិធាន និងនីតិវិធីសម្រាប់គ្រប់គ្រងអ្នកប្រកបវិជ្ជាជីវៈ សុខាភិបាល និងការប្រកបវិជ្ជាជីវៈសុខាភិបាល ។

**មាត្រា ៣.-**

ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះអ្នកប្រកបវិជ្ជាជីវៈសុខាភិបាលទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៤.-**

វាក្យសព្ទបច្ចេកទេសសំខាន់ៗដែលប្រើក្នុងច្បាប់នេះមាននិយមន័យដូចតទៅ ៖

**អ្នកវិជ្ជាជីវៈសុខាភិបាល** សំដៅដល់គ្រូពេទ្យ ទន្តពេទ្យ ឆ្មប គិលានុបដ្ឋាក ឱសថការី អ្នកបច្ចេកទេសមន្ទីរពិសោធន៍សុខាភិបាល អ្នកព្យាបាលដោយចលនា ទន្តគិលានុបដ្ឋាក អ្នកបច្ចេកទេសវិទ្យុសាស្ត្រ និងអ្នកវិជ្ជាជីវៈសុខាភិបាលផ្សេងទៀតដែលទទួលបានការចុះ បញ្ជិកាជាមួយគណៈវិជ្ជាជីវៈសុខាភិបាលពាក់ព័ន្ធ ។

**អ្នកប្រកបវិជ្ជាជីវៈសុខាភិបាល** សំដៅដល់អ្នកវិជ្ជាជីវៈសុខាភិបាលដែលទទួល បានអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈ ។

**ការប្រកបវិជ្ជាជីវៈសុខាភិបាល** សំដៅដល់ការអនុវត្តវិជ្ជាជីវៈដែលស្ថិតនៅក្នុងដែនកំណត់វិជ្ជាជីវៈសុខាភិបាលនៃមុខវិជ្ជាជីវៈសុខាភិបាលនីមួយៗ ។

**បញ្ជីគណៈវិជ្ជាជីវៈសុខាភិបាល** សំដៅដល់បញ្ជីគណៈគ្រូពេទ្យកម្ពុជា បញ្ជីគណៈទន្តពេទ្យកម្ពុជា បញ្ជីគណៈឱសថការីកម្ពុជា បញ្ជីគណៈឆ្មបកម្ពុជា បញ្ជីគណៈគិលានុបដ្ឋាកកម្ពុជា និងបញ្ជីគណៈវិជ្ជាជីវៈសុខាភិបាលផ្សេងៗទៀត ដែលមានកំណត់ត្រានៃឈ្មោះ និងព័ត៌មានផ្សេងៗរបស់អ្នកវិជ្ជាជីវៈសុខាភិបាលនិងអ្នកប្រកបវិជ្ជាជីវៈសុខាភិបាល តាមបញ្ញត្តិនៃច្បាប់នេះ ហើយបញ្ជីនេះត្រូវគ្រប់គ្រងដោយគណៈវិជ្ជាជីវៈសុខាភិបាលនីមួយៗដែលពាក់ព័ន្ធ ។

**ការចុះបញ្ជិកា** សំដៅដល់ដំណើរការនៃការចុះបញ្ជីបុគ្គលម្នាក់ទៅជាអ្នកវិជ្ជាជីវៈសុខាភិបាល ។

ROYAUME DU CAMBODGE
LE MINISTÈRE DU PALAIS ROYAL

អាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសុខាភិបាល សំដៅដល់ការអនុញ្ញាតឲ្យប្រកបវិជ្ជាជីវៈសុខាភិបាល ដែលផ្តល់ដោយគណៈវិជ្ជាជីវៈសុខាភិបាលនីមួយៗ បន្ទាប់ពីមានការចុះបញ្ជិកា និងការបំពេញលក្ខខណ្ឌ ដើម្បីទទួលបានអាជ្ញាបណ្ណស្របតាមបញ្ញត្តិនៃច្បាប់នេះ ។

កំហុសឆ្គងវិជ្ជាជីវៈសុខាភិបាល សំដៅដល់រាល់កំហុសឆ្គងទាំងឡាយដែលខុសនឹង ក្រមសីលធម៌វិជ្ជាជីវៈ បទដ្ឋានវិជ្ជាជីវៈ និយាមវិជ្ជាជីវៈ និងដែនកំណត់វិជ្ជាជីវៈសុខាភិបាល ដោយអ្នកប្រកបវិជ្ជាជីវៈសុខាភិបាល ។

## ជំពូកទី ២
## សមត្ថកិច្ចគ្រប់គ្រង

**មាត្រា ៥.-**

គណៈវិជ្ជាជីវៈសុខាភិបាលនីមួយៗមានសមត្ថកិច្ចក្នុងការចុះបញ្ជិកានិងផ្តល់អាជ្ញា បណ្ណប្រកបវិជ្ជាជីវៈសុខាភិបាល ព្រមទាំងគ្រប់គ្រងអ្នកប្រកបវិជ្ជាជីវៈសុខាភិបាល ។

បទប្បញ្ញត្តិស្តីពីបទដ្ឋានវិជ្ជាជីវៈ និងនិយាមវិជ្ជាជីវៈ ត្រូវកំណត់ដោយគណៈវិជ្ជាជីវៈសុខាភិបាលពាក់ព័ន្ធ ។

## ជំពូកទី ៣
## ការប្រកបវិជ្ជាជីវៈសុខាភិបាល

**មាត្រា ៦.-**

បុគ្គលទាំងឡាយដែលមានបំណងប្រកបវិជ្ជាជីវៈសុខាភិបាលត្រូវ ៖

-ចុះបញ្ជិកាក្នុងបញ្ជីគណៈវិជ្ជាជីវៈសុខាភិបាល

-មានអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសុខាភិបាល ។

**មាត្រា ៧.-**

ក្នុងការប្រកបវិជ្ជាជីវៈសុខាភិបាល អ្នកប្រកបវិជ្ជាជីវៈសុខាភិបាលត្រូវ ៖

-មានអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសុខាភិបាល ដែលមានសុពលភាព

-គោរពក្រមសីលធម៌វិជ្ជាជីវៈ បទដ្ឋានវិជ្ជាជីវៈ និងនិយាមវិជ្ជាជីវៈ

-អនុវត្តការងារក្នុងដែនកំណត់វិជ្ជាជីវៈសុខាភិបាល ។

**មាត្រា ៨.-**

បុគ្គលដែលអាចស្នើសុំចុះបញ្ជិកា ត្រូវបំពេញលក្ខខណ្ឌអប្បបរមាដូចខាងក្រោម ៖

-មានគុណវុឌ្ឍិក្នុងវិជ្ជាជីវៈរបស់ខ្លួន ដោយមានការទទួលស្គាល់ពីក្រសួងសុខាភិបាល

-មិនធ្លាប់ត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋណាមួយ

ROYAUME DU CAMBODGE
LE MINISTÈRE ... ROYAL
ព្រះរាជាណាចក្រកម្ពុជា

- មិនមានបញ្ហាសុខភាពខាងផ្លូវកាយ ឬផ្លូវចិត្តដែលអាចប៉ះពាល់ដល់ការប្រកបវិជ្ជាជីវៈរបស់ខ្លួន
- ការស្នើសុំចុះបញ្ជិកាត្រូវធ្វើនៅគណៈវិជ្ជាជីវៈសុខាភិបាលពាក់ព័ន្ធ ។

បែបបទ នីតិវិធី និងលក្ខខណ្ឌតម្រូវផ្សេងៗទៀតក្នុងការចុះបញ្ជិកា ត្រូវកំណត់ដោយគណៈ-វិជ្ជាជីវៈសុខាភិបាលនីមួយៗដែលពាក់ព័ន្ធ ។

**មាត្រា ៩.-**

អ្នកវិជ្ជាជីវៈសុខាភិបាលដែលអាចដាក់ពាក្យស្នើសុំអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសុខាភិបាលត្រូវបំពេញលក្ខខណ្ឌអប្បបរមាដូចខាងក្រោម ៖

- បានចុះបញ្ជិកាជាមួយគណៈវិជ្ជាជីវៈសុខាភិបាលពាក់ព័ន្ធ
- រក្សាបាននិយាមតម្រូវសម្រាប់សមត្ថភាពក្នុងការប្រកបវិជ្ជាជីវៈសុខាភិបាល
- បង្ហាញថាមានបច្ចុប្បន្នភាពសមត្ថភាព ឬបទពិសោធថ្មីៗដែលច្បាប់តម្រូវសម្រាប់ការប្រកបវិជ្ជាជីវៈ
- មិនធ្លាប់ត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋណាមួយ នៅក្នុងប្រទេសកម្ពុជា ឬនៅក្នុងប្រទេសណាមួយដែលខ្លួនធ្លាប់ស្នាក់នៅ
- មិនមានបញ្ហាសុខភាពផ្លូវកាយ ឬផ្លូវចិត្តដែលអាចប៉ះពាល់ដល់ការប្រកបវិជ្ជាជីវៈសុខាភិបាល
- ការស្នើសុំអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសុខាភិបាលត្រូវធ្វើនៅគណៈវិជ្ជាជីវៈ សុខាភិបាលនីមួយៗដែលពាក់ព័ន្ធ ។

បែបបទ នីតិវិធី និងលក្ខខណ្ឌតម្រូវផ្សេងៗទៀតក្នុងការផ្តល់អាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសុខាភិបាល ត្រូវកំណត់ដោយគណៈវិជ្ជាជីវៈសុខាភិបាលនីមួយៗដែលពាក់ព័ន្ធ ។

**មាត្រា ១០.-**

លក្ខខណ្ឌ និងនីតិវិធីក្នុងការបន្តអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសុខាភិបាលត្រូវកំណត់ដោយ គណៈ-វិជ្ជាជីវៈសុខាភិបាលដែលពាក់ព័ន្ធ ។

**មាត្រា ១១.-**

ជនបរទេសដែលមានបំណងប្រកបវិជ្ជាជីវៈសុខាភិបាលនៅក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវដាក់ពាក្យស្នើសុំចុះបញ្ជិកា និងអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសុខាភិបាល នៅគណៈវិជ្ជាជីវៈសុខាភិបាលពាក់ព័ន្ធណាមួយស្របតាមមុខវិជ្ជាជីវៈរបស់ខ្លួន ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា ១២.-**

ដែនកំណត់វិជ្ជាជីវៈសុខាភិបាលនៃមុខវិជ្ជាជីវៈសុខាភិបាលនីមួយៗ ត្រូវកំណត់ដោយគណៈវិជ្ជាជីវៈ សុខាភិបាលដែលពាក់ព័ន្ធដោយមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងសុខាភិបាល ។

## ជំពូកទី ៤
## សម្បទាក្នុងការប្រកបវិជ្ជាជីវៈ

**មាត្រា ១៣.-**

អ្នកប្រកបវិជ្ជាជីវៈសុខាភិបាលអាចត្រូវបានចាត់ទុកថាមិនមានសម្បទាក្នុងការប្រកបវិជ្ជាជីវៈសុខាភិបាល ប្រសិនបើ ៖

- មិនបានបំពេញតាមលក្ខខណ្ឌតម្រូវពាក់ព័ន្ធនឹងអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសុខាភិបាល ដែលកំណត់ដោយគណៈវិជ្ជាជីវៈសុខាភិបាលដែលពាក់ព័ន្ធ
- បានប្រព្រឹត្តកំហុសឆ្គងវិជ្ជាជីវៈសុខាភិបាល ដែលនាំទៅដល់ការផ្អាកអាជ្ញាបណ្ណវិជ្ជាជីវៈសុខាភិបាលជាបណ្តោះអាសន្ន ឬការដកហូតអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសុខាភិបាលជាស្ថាពរ
- មានការបញ្ជាក់ថាមានបញ្ហាសុខភាពផ្លូវកាយ ឬផ្លូវចិត្តដែលអាចប៉ះពាល់ដល់ការប្រកបវិជ្ជាជីវៈរបស់ខ្លួន ឬ
- ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋនៅក្នុងប្រទេសកម្ពុជា ឬនៅក្នុងប្រទេសណាមួយដែលខ្លួនធ្លាប់ស្នាក់នៅ ។

**មាត្រា ១៤.-**

គណៈវិជ្ជាជីវៈសុខាភិបាលដែលពាក់ព័ន្ធ អាចធ្វើការត្រួតពិនិត្យសម្បទាក្នុងការប្រកបវិជ្ជាជីវៈរបស់អ្នកប្រកបវិជ្ជាជីវៈសុខាភិបាលបានគ្រប់ពេលវេលា ។

គណៈវិជ្ជាជីវៈសុខាភិបាលនីមួយៗដែលពាក់ព័ន្ធ ត្រូវធ្វើការពិនិត្យរាល់បណ្តឹង ឬការរាយការណ៍ដែលពាក់ព័ន្ធនឹងសម្បទាក្នុងការប្រកបវិជ្ជាជីវៈរបស់អ្នកប្រកបវិជ្ជាជីវៈសុខាភិបាល ។

បែបបទ នីតិវិធី និងលក្ខខណ្ឌដែលពាក់ព័ន្ធនឹងការត្រួតពិនិត្យសម្បទាក្នុងការប្រកបវិជ្ជាជីវៈរបស់អ្នកប្រកបវិជ្ជាជីវៈសុខាភិបាល និងការពិនិត្យរាល់បណ្តឹង ឬការរាយការណ៍ខាងលើ ត្រូវកំណត់ដោយគណៈវិជ្ជាជីវៈសុខាភិបាលដែលពាក់ព័ន្ធ ។

## ជំពូកទី ៥
## ទណ្ឌកម្មខាងវិន័យ និងបណ្តឹងតវ៉ា

**មាត្រា ១៥.-**

ចំពោះអ្នកប្រកបវិជ្ជាជីវៈសុខាភិបាលដែលបានប្រព្រឹត្តកំហុសឆ្គងវិជ្ជាជីវៈសុខាភិបាល ដែលពាក់ព័ន្ធ ឬមិនមានសម្បទាគ្រប់គ្រាន់ក្នុងការប្រកបវិជ្ជាជីវៈ គណៈវិជ្ជាជីវៈសុខាភិបាល ដែលពាក់ព័ន្ធ អាចដាក់ទណ្ឌកម្មខាងវិន័យដូចខាងក្រោម ៖

- ធ្វើការព្រមាន
- ធ្វើការកត់ទុកក្នុងឯកសារផ្ទាល់ខ្លួន
- កំណត់លក្ខខណ្ឌផ្សេងៗចំពោះការប្រកបវិជ្ជាជីវៈសុខាភិបាលក្នុងរយៈពេលកំណត់ណាមួយ ឬជាស្ថាពរ
- ផ្អាកអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសុខាភិបាលជាបណ្តោះអាសន្ន
- ដកហូតអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសុខាភិបាលជាស្ថាពរ
- លុបឈ្មោះចេញពីបញ្ជីគណៈវិជ្ជាជីវៈសុខាភិបាលពាក់ព័ន្ធ ។

លក្ខណវិនិច្ឆ័យក្នុងការអនុវត្តទណ្ឌកម្មខាងវិន័យ ត្រូវកំណត់ដោយគណៈវិជ្ជាជីវៈសុខាភិបាល ដែលពាក់ព័ន្ធ ។

**មាត្រា ១៦.-**

ចំពោះរាល់បណ្តឹងទាក់ទងនឹងកំហុសឆ្គងវិជ្ជាជីវៈសុខាភិបាល ភាគីពាក់ព័ន្ធ មានសិទ្ធិប្តឹងជាមុនទៅគណៈវិជ្ជាជីវៈសុខាភិបាលដែលពាក់ព័ន្ធ ។

នីតិវិធីលើបណ្តឹងពាក់ព័ន្ធនឹងកំហុសឆ្គងវិជ្ជាជីវៈសុខាភិបាល ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ១៧.-**

រាល់ការវិនិច្ឆ័យ និងនីតិវិធីរបស់តុលាការ ឬស្ថាប័នមានសមត្ថកិច្ចផ្សេងៗពាក់ព័ន្ធនឹងការប្រព្រឹត្តរបស់អ្នកប្រកបវិជ្ជាជីវៈសុខាភិបាល ចាំបាច់ត្រូវមានការចូលរួមពីគណៈវិជ្ជាជីវៈសុខាភិបាលដែលពាក់ព័ន្ធ ។

**មាត្រា ១៨.-**

គណៈវិជ្ជាជីវៈសុខាភិបាល អាចផ្អាកអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសុខាភិបាលបណ្តោះអាសន្នជាបន្ទាន់ ក្នុងករណីដែលមានហេតុផលសមស្របសង្ស័យថា អ្នកប្រកបវិជ្ជាជីវៈសុខាភិបាលណាម្នាក់

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL · ក្រសួងព្រះបរមរាជវាំង

បានប្រព្រឹត្តកំហុសធ្ងន់វិជ្ជាជីវៈសុខាភិបាល ដែលនាំឲ្យប៉ះពាល់ដល់ជីវិតមនុស្ស ហើយដែលអាចបន្តបង្កគ្រោះថ្នាក់ដល់អ្នកផ្សេងទៀត ។

**មាត្រា ១៩.-**

គណៈវិជ្ជាជីវៈសុខាភិបាលនីមួយៗដែលពាក់ព័ន្ធ អាចផ្អាកអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសុខាភិបាលជាបណ្តោះអាសន្ន ក្នុងករណីណាមួយដូចខាងក្រោម ៖

- មានបញ្ហាសុខភាពផ្លូវកាយ ឬផ្លូវចិត្តដែលអាចប៉ះពាល់ដល់ការប្រកបវិជ្ជាជីវៈសុខាភិបាល
- នៅតែប្រព្រឹត្តកំហុសធ្ងន់វិជ្ជាជីវៈសុខាភិបាលដែលគណៈវិជ្ជាជីវៈធ្លាប់ព្រមាន រួចហើយ ឬប្រព្រឹត្តខុសនឹងលក្ខខណ្ឌតម្រូវផ្សេងៗ
- ក្នុងករណីផ្សេងទៀតដែលគណៈវិជ្ជាជីវៈសុខាភិបាល រកឃើញថាមិនមានសម្បទាគ្រប់គ្រាន់ក្នុងការប្រកបវិជ្ជាជីវៈសុខាភិបាល ។

បុគ្គលដែលត្រូវបានគណៈវិជ្ជាជីវៈសុខាភិបាលនីមួយៗសម្រេចផ្អាកមិនឲ្យប្រកបវិជ្ជាជីវៈសុខាភិបាលជាបណ្តោះអាសន្ន អាចស្នើសុំអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសុខាភិបាលឡើងវិញ ដោយអនុលោមទៅតាមលក្ខខណ្ឌ និងនីតិវិធីដែលត្រូវកំណត់ដោយគណៈវិជ្ជាជីវៈសុខាភិបាលដែលពាក់ព័ន្ធ ។

**មាត្រា ២០.-**

គណៈវិជ្ជាជីវៈសុខាភិបាលដែលពាក់ព័ន្ធត្រូវលុបឈ្មោះចេញពីបញ្ជីគណៈវិជ្ជាជីវៈសុខាភិបាល និងដកហូតអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសុខាភិបាល ចំពោះអ្នកប្រកបវិជ្ជាជីវៈសុខាភិបាលទាំងឡាយណាដែលត្រូវបានតុលាការសម្រេចជាស្ថាពរថាមានទោសពីបទឧក្រិដ្ឋ ឬត្រូវបានតុលាការហាមឃាត់មិនឲ្យប្រកបវិជ្ជាជីវៈសុខាភិបាលជាអចិន្ត្រៃយ៍ ។

**មាត្រា ២១.-**

បុគ្គលដែលមិនសុខចិត្តនឹងសេចក្តីសម្រេចអំពីទណ្ឌកម្មខាងវិន័យ ដែលធ្វើឡើងដោយគណៈ-វិជ្ជាជីវៈសុខាភិបាលដែលពាក់ព័ន្ធ មានសិទ្ធិប្តឹងទៅតុលាការមានសមត្ថកិច្ចក្នុងរយៈពេល ៣០(សាមសិប) ថ្ងៃ ក្រោយពីបានទទួលសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីសេចក្តីសម្រេចនោះ ។

**មាត្រា ២២.-**

ការទទួលរងទណ្ឌកម្មខាងវិន័យ មិនអាចធ្វើឲ្យអ្នកប្រកបវិជ្ជាជីវៈសុខាភិបាលដែលប្រព្រឹត្តខុសរួចផុតពីការទទួលខុសត្រូវខាងរដ្ឋប្បវេណី ឬ/និងការទទួលខុសត្រូវខាងព្រហ្មទណ្ឌដែលមានចែងនៅក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមានឡើយ ។

ROYAUME du CAMBODGE LE MINISTRE du PALAIS ROYAL

## ជំពូកទី ៦
## បទប្បញ្ញត្តិដោយឡែក

**មាត្រា ២៣.-**

ការគ្រប់គ្រងអ្នកប្រកបវិជ្ជាជីវៈវេជ្ជសាស្ត្របុរាណ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ២៤.-**

ការគ្រប់គ្រងអ្នកប្រកប វិជ្ជាជីវៈសុខាភិបាលផ្សេងទៀតដែលមិនទាន់បានបង្កើតគណៈវិជ្ជាជីវៈរបស់ខ្លួន ត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ៧
## ទោសប្បញ្ញត្តិ

**មាត្រា ២៥.-**

ជនណាដែលបានក្លែងអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសុខាភិបាលត្រូវផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌជាធរមាន ។

**មាត្រា ២៦.-**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ៥ ០០០ ០០០ (ប្រាំលាន) រៀល ទៅ ១០ ០០០ ០០០ (ដប់លាន) រៀល ចំពោះជនណាដែលមិនមែនជាអ្នក វិជ្ជាជីវៈសុខាភិបាល ហើយបានប្រកបវិជ្ជាជីវៈសុខាភិបាល ។

**មាត្រា ២៧.-**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ៥ ០០០ ០០០(ប្រាំលាន) រៀល ទៅ ១០ ០០០ ០០០(ដប់លាន) រៀល ចំពោះអ្នកប្រកបវិជ្ជាជីវៈសុខាភិបាលដែលគណៈវិជ្ជាជីវៈសុខាភិបាលពាក់ព័ន្ធនីមួយៗបានផ្អាកមិនឲ្យប្រកបវិជ្ជាជីវៈសុខាភិបាលជាបណ្តោះអាសន្ន ហើយនៅតែប្រកបវិជ្ជាជីវៈសុខាភិបាល ។

**មាត្រា ២៨.-**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ២ ០០០ ០០០ (ពីរលាន) រៀល ទៅ ៥ ០០០ ០០០(ប្រាំលាន) រៀល ចំពោះអ្នកវិជ្ជាជីវៈសុខា-ភិបាលដែលប្រកប វិជ្ជាជីវៈសុខាភិបាលដោយគ្មានអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសុខាភិបាល ។

**មាត្រា ២៩.-**

ត្រូវពិន័យជាប្រាក់ពី ២ ០០០ ០០០(ពីរលាន) រៀល ទៅ ៥ ០០០ ០០០ (ប្រាំលាន) រៀល ចំពោះអ្នកប្រកបវិជ្ជាជីវៈសុខាភិបាលដែលប្រកបវិជ្ជាជីវៈសុខាភិបាលដោយអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសុខាភិបាលអស់សុពលភាព ។

**មាត្រា ៣០.-**

ត្រូវពិន័យជាប្រាក់ពី ២ ០០០ ០០០(ពីរលាន) រៀល ទៅ ៥ ០០០ ០០០(ប្រាំលាន) រៀល ចំពោះអ្នកប្រកបវិជ្ជាជីវៈសុខាភិបាលដែលប្រកបវិជ្ជាជីវៈសុខាភិបាលដោយរំលោភបំពានដែនកំណត់វិជ្ជាជីវៈសុខាភិបាល ឬបំពានលើលក្ខខណ្ឌដែលបានកំណត់ចំពោះការប្រកបវិជ្ជាជីវៈសុខាភិបាល ។

ករណីដែលទទួលរងការពិន័យម្តងរួចហើយ នៅតែបន្តប្រព្រឹត្តបទល្មើសដដែលត្រូវ ផ្តន្ទាទោសពិន័យជាប្រាក់ទ្វេដង ។

## ជំពូកទី ៨
## អន្តរប្បញ្ញត្តិ

**មាត្រា ៣១.-**

បន្ទាប់ពីច្បាប់នេះចូលជាធរមានក្នុងរយៈពេលយ៉ាងយូរ ៦ (ប្រាំមួយ) ខែ ក្រសួងសុខាភិបាលត្រូវបង្កើតគណៈកម្មការមួយដែលរួមមានគណៈវិជ្ជាជីវៈសុខាភិបាលនីមួយៗ និងនាយកដ្ឋានដែលពាក់ព័ន្ធនៃក្រសួងសុខាភិបាល ។ ប្រធាននៃគណៈកម្មការនេះ គឺជារដ្ឋលេខាធិការនៃក្រសួងសុខាភិបាល ។

ការរៀបចំ និងលក្ខខណ្ឌប្រតិបត្តិរបស់គណៈកម្មការនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល ។

គណៈកម្មការនេះ មានភារកិច្ចណែនាំ និងដឹកនាំដើម្បីសម្របសម្រួល ក្នុងការកសាងសមត្ថភាពរបស់គណៈវិជ្ជាជីវៈសុខាភិបាលនីមួយៗ ដើម្បីបំពេញតួនាទីនិងភារកិច្ចដូចមានចែងក្នុងច្បាប់នេះ ។

ក្នុងរយៈពេល ៥(ប្រាំ) ឆ្នាំ ដំបូងនៃការអនុវត្តច្បាប់នេះ គណៈវិជ្ជាជីវៈសុខាភិបាលអាចទទួលបាននូវថវិកាប្រតិបត្តិប្រចាំឆ្នាំពីរាជរដ្ឋាភិបាលកម្ពុជា ក្នុងការកសាងសមត្ថភាពរបស់ខ្លួន ដើម្បីបំពេញតួនាទីនិងភារកិច្ច ដូចមានចែងក្នុងច្បាប់នេះ ។

**មាត្រា ៣២.-**

រាល់អ្នកវិជ្ជាជីវៈសុខាភិបាលដែលការចុះបញ្ជិកានៅមានសុពលភាពមុនពេលច្បាប់នេះចូលជាធរមាន នៅបន្តសុពលភាពក្រោមបទប្បញ្ញត្តិនៃច្បាប់នេះ ។

**មាត្រា ៣៣.-**

បន្ទាប់ពីច្បាប់នេះចូលជាធរមាន អ្នកវិជ្ជាជីវៈសុខាភិបាលមានរយៈពេល ១២ (ដប់ពីរ) ខែយ៉ាងយូរ ដើម្បីមកដាក់ពាក្យស្នើសុំអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសុខាភិបាល ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

**មាត្រា ៣៤.-**

លិខិតបទដ្ឋានគតិយុត្តទាំងឡាយដែលពាក់ព័ន្ធនឹងការគ្រប់គ្រងអ្នកប្រកបវិជ្ជាជីវៈសុខាភិបាលនៅបន្តអនុវត្តរហូតមានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួស ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

## ជំពូកទី ៩
## អវសានប្បញ្ញត្តិ

**មាត្រា ៣៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ២០១៦

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

នស/រកម.១១១៦.០១៧

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**
**ហត្ថលេខា**
**ម៉ម ប៊ុនហេង**

លេខ:១០៦៧ស.ណ
សំណៅដែលមានគុណតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែវិច្ឆិកា ឆ្នាំ២០១៦
អគ្គលេខាធិការរាជរដ្ឋាភិបាល
ស៊ុយ សុខា